# បុព្វកថា

កម្មវិធីគាំទ្រវិស័យអប់រំឆ្នាំ២០០៤-០៨ បានឆ្លុះបញ្ចាំងឱ្យឃើញនូវដំណាក់កាលដ៏សំខាន់មួយទៀត ក្នុងដំណើរការកែទម្រង់វិស័យអប់រំ ។ កម្មវិធីគាំទ្រវិស័យអប់រំឆ្នាំ២០០៤-០៨ ត្រូវបានតាក់តែងឡើង ដើម្បីបង្ហាញពីប្រព័ន្ធការងារ កម្មវិធី និង ធនធានរបស់ក្រសួងអប់រំ យុវជន និង កីឡា ដែលនឹងត្រូវអនុវត្តតាមផែនការយុទ្ធសាស្ត្រចតុកោណនៃរាជរដ្ឋាភិបាលក្នុងវិស័យអប់រំឆ្នាំ ២០០៤-០៨ ។

ការពិនិត្យឡើងវិញ លើការបំពេញការងារវិស័យអប់រំប្រចាំឆ្នាំ២០០៤បានវាយតម្លៃថា វិស័យអប់រំបានទទួលជោគជ័យជាងឆ្នាំកន្លងមក ។ ដើម្បីឈានឆ្ពោះឱ្យបានសម្រេចគោលដៅអប់រំ ក្រសួងត្រូវពង្រឹងកំណែទម្រង់គ្រប់ផ្នែក រួមទាំងសមត្ថភាព ហិរញ្ញវត្ថុ និង ស្ថាប័នឱ្យបានទូលំទូលាយថែមទៀត ។

អាស្រ័យហេតុនេះ ក្រសួងត្រូវបន្តការពិភាក្សាឱ្យបានទូលំទូលាយ ជាមួយក្រសួងពាក់ព័ន្ធ ភាគីផ្តល់ជំនួយ និង អង្គការក្រៅរដ្ឋាភិបាលលើបញ្ហាខាងលើឱ្យបានពិស្តារ ។ កន្លងមកនេះ ការពិភាក្សាបានរួមចំណែកយ៉ាងសកម្មលើការកែសម្រួលឯកសារកម្មវិធីគាំទ្រវិស័យអប់រំឆ្នាំ២០០៤-០៨ ។

កម្មវិធីគាំទ្រវិស័យអប់រំឆ្នាំ២០០៤-០៨ បានលើកឡើងអំពីអាទិភាពកម្មវិធី និង ការបែងចែកធនធានសំរាប់យកទៅអនុវត្តនៅដំណាក់កាលកែទម្រង់វិស័យអប់រំនាពេលខាងមុខ ។ ដំណើរការអភិវឌ្ឍន៍ក៏បានផ្តល់ឱកាស ដើម្បីជួយដល់ការកសាងសមត្ថភាព និង អភិវឌ្ឍស្ថាប័ននៅពេលអនាគត ដោយធ្វើការពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍន៍ឱ្យបានពេញលេញ ។

ឆ្លៀតឱកាសនេះ ខ្ញុំសូមសំដែងអំណរគុណដ៏ជ្រាលជ្រៅជាទីបំផុតចំពោះសម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ប្រមុខរាជរដ្ឋាភិបាល ដែលសម្តេចបានផ្តល់នូវទស្សនៈវិស័យ និង គាំទ្រយ៉ាងម៉ឺងម៉ាត់ក្នុងការពង្រឹងវិស័យអប់រំជាតិ ចំពោះថ្នាក់ដឹកនាំ និង មន្ត្រីបច្ចេកទេសទាំងអស់របស់ក្រសួងអប់រំ យុវជន និង កីឡា ដែលបានប្រឹងប្រែងអស់ពីកម្លាំងកាយ កម្លាំងចិត្តក្នុងការកសាងឯកសារដ៏មានតម្លៃនេះ ។ ម្យ៉ាងទៀត ខ្ញុំក៏សូមសំដែងអំណរគុណដ៏ស្មោះចំពោះដៃគូអ្នកផ្តល់ជំនួយ និង សហគមន៍អង្គការក្រៅរដ្ឋាភិបាល ក្នុងការបន្តការជំរុញលើកទឹកចិត្ត និង ការគាំទ្រដល់វិស័យអប់រំ យុវជន និង កីឡា ។

ក្រសួងនឹងខំអនុវត្តកំណែទម្រង់ បណ្តុះបណ្តាលធនធានមនុស្សនេះ ឱ្យទទួលបានជោគជ័យសំរាប់អនាគតដ៏ភ្លឺស្វាងរបស់ប្រជាពលរដ្ឋខ្មែរគ្រប់ៗរូប ។

**គឹម ឆេង**

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា